ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

លេខ : ៣៨ | ២០១៧ កបធ.សសរ

# សេចក្ដីសម្រេច

## ស្ដីពី

## វិសោធនកម្មប្រការ ៤ ប្រការ ៧ និងប្រការ ៨ នៃបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៨
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើវិសោធនកម្មនាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៨
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើវិសោធនកម្មនាថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៧

## សម្រេច

**ប្រការមួយ.-**

ប្រការ ៤ ប្រការ ៧ និងប្រការ ៨ នៃបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានធ្វើវិសោធកម្មដូចតទៅ ៖

**ប្រការ ៤ ថ្មី.-**

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងមុខតំណែងរបស់ខ្លួនមិនត្រូវ ៖

- កាន់កាប់ជាប្រធាន-អនុប្រធានគណបក្សនយោបាយ ប្រធាន-អនុប្រធានសហជីព ហើយជាទូទៅបំពេញនូវសកម្មភាព ដែលមិនអាចស្រុះស្រួលគ្នាបានជាមួយបទប្បញ្ញត្តិ នៃប្រការ ៣ ខាងលើ។
- បណ្តោយឱ្យធ្វើនិទ្ទេសអំពីតួនាទីរបស់ខ្លួន ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងឯកសារដែលអាចយកទៅបោះពុម្ពផ្សាយ និងទាក់ទងទៅនឹងគ្រប់សកម្មភាពសាធារណៈ ឬឯកជន។

**ប្រការ ៧ ថ្មី.-**

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាធម្មនុញ្ញនឹងវាយតម្លៃសមាជិករបស់ខ្លួនណាដែលខ្វះខាតមិនបានបំពេញកាតព្វកិច្ចជាទូទៅ ជាពិសេសកាតព្វកិច្ចដែលមានចែងក្នុងប្រការ ៣ និងប្រការ ៤ថ្មី នៃបទបញ្ជាផ្ទៃក្នុងនេះ។

**ប្រការ ៨ ថ្មី.-**

ក្នុងករណីដែលមានចែងក្នុងប្រការ ៧ ថ្មី ខាងលើ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចដោយបោះឆ្នោតសម្ងាត់ យកតាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល (៥ សំឡេងយ៉ាងតិច)។

**ប្រការពីរ.-**

វិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញនេះ ត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញអនុម័តនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៧ ក្នុងកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ហើយត្រូវបានដាក់ឱ្យអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៧

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**អ៊ឹម ឈុនលឹម**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"
- ឯកសារ- កាលប្បវត្តិ